សាលាកប័ត្រពត៌មានប្រចាំខែ
KRT WATCH
លេខ: ០១ ខែ កក្កដា ឆ្នាំ ២០០៥

# ឃ្លាំមើល សាលាក្តីខ្មែរក្រហម

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CCPCR - CDP - CHHRA - CKIMHRDA - CWCC - GENEROUS - IDA - KKKHRA - KKKHRDA - KID - KSA - KYA - LAC - LICADHO - OUTREACH - TASK FORCE - VIGILANCE

## គណៈកម្មាធិការប្រព្រឹត្តិកម្ម អំពាវនាវឱ្យមានអង្គជំនុំជំរះវិសាមញ្ញស្របតាមបទដ្ឋានអន្តរជាតិ

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា បានចេញសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ អំពាវនាវឱ្យមានការជ្រើសរើសចៅក្រម ព្រះរាជអាជ្ញាកម្ពុជាដែលទៅបំរើការនៅក្នុងអង្គជំនុំជំរះវិសាមញ្ញប្រកបដោយលក្ខណៈត្រឹមត្រូវ អាចទទួលយកបាន និងឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិ ព្រមទាំងថវិកាចាំបាច់សំរាប់ឱ្យប្រើប្រាស់ក្នុងការការពារជនរងគ្រោះ និងសាក្សីផងដែរ។ ចំណុចសំខាន់ៗ ដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍នោះ រួមមានដូចខាងក្រោមៈ

- ការជ្រើសរើសចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកជាតិឱ្យទៅបំរើការនៅក្នុងអង្គជំនុំជំរះវិសាមញ្ញត្រូវមានលក្ខណៈប្រកបដោយតម្លាភាព យុត្តិធម៌ និងមានការកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់។
- ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកអន្តរជាតិត្រូវតែមានជំនាញវិជ្ជាជីវៈខ្ពស់ ជាពិសេសបំពេញមុខងាររបស់ខ្លួនដោយសេរី មិនទទួលរងនូវឥទ្ធិពលពីសំណាក់អ្នកមានអំណាច ឬរាជរដ្ឋាភិបាល ហើយការជ្រើសរើសក៏ត្រូវតែធ្វើឡើងជាសាធារណៈដែរ ។
- ថវិកាសំរាប់ប្រើប្រាស់ក្នុងអង្គជំនុំជំរះវិសាមញ្ញ ត្រូវតែគ្រប់គ្រាន់ស្របតាមបទដ្ឋានអន្តរជាតិដែលបានទទួល ។
- ត្រូវតែមានថវិកា និងគំរោងច្បាស់លាស់ក្នុងការផ្តល់សេវាគាំទ្រ និងការជួយការពារដល់ជនរងគ្រោះ និងសាក្សី ។
- ត្រូវធ្វើឱ្យបានឆាប់រហ័ស និងមានភាពច្បាស់លាស់ស្តីពីវិធានស្តីពីនីតិវិធី និងភស្តុតាង។

## គង្វះថវិកាសំរាប់ដំណើរការសាលាក្តី នៅតែចោទជាបញ្ហា

បញ្ហាថវិកាសំរាប់ដំណើរការអង្គជំនុំជំរះវិសាមញ្ញត្រូវបានចោទជាបញ្ហាចំពោះមុខដែលធ្វើឱ្យអង្គជំនុំជំរះនេះមិនអាចចាប់ដំណើរការរបស់ខ្លួនបានរហូតមកទល់ពេលនេះ។ មានការលើកឡើងដោយឡែកពីគ្នារវាងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជានិងមន្ត្រីទទួលបន្ទុកការងារសាលាក្តីជំនុំជម្រះក្តីខ្មែរក្រហម។ កាលពីខែមិថុនាកន្លងទៅនេះ ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានថ្លែងអំពីការបញ្ចប់ការទន្ទឹងរង់ចាំថវិកាបង្គ្រប់ដែលជាចំណែករបស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបំពេញចំនួន ១១.៨លានដុល្លាអាមេរិកបន្ថែមទៅលើថវិកាទាំងមូលរបស់សាលាក្តី ដោយបានលើកឡើងថា ភាគីជប៉ុនសន្យាជួយចេញបង្គ្រប់។ ផ្ទុយទៅវិញ នៅក្នុងឱកាសសិក្ខាសាលាមួយដែលបានរៀបចំឡើងដោយសាកលវិទ្យាល័យកម្ពុជា កាលពីថ្ងៃទី ១៤ ខែកក្កដា នេះ ឯកឧត្តម **ស៊ាន វិសុទ្ធ** អគ្គលេខាធិការអចិន្ត្រៃយ៍នៃក្រុមការងារជំនុំជំម្រះក្តីខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលនៅកំពុងរង់ចាំអ្នកផ្តល់ជំនួយអន្តរជាតិនៅឡើយ ដើម្បីចេញចំណាយលើថវិកាដែលនៅខ្វះខាតចំនួន ១១.៨ លានដុល្លារ សំរាប់សាលាក្តីខ្មែរក្រហម និងរង់ចាំខាងភាគីអង្គការសហប្រជាជាតិតែងតាំងអនុប្រធានអ្នកសំរបសំរួលមួយរូបសិនមុននឹងដំណើរការទៅមុខ។ ឯកឧត្តមក៏បានសង្កត់ធ្ងន់ថារាជរដ្ឋាភិបាលមិនមានកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលជប៉ុនក្នុងការប្រើប្រាស់ជំនួយទ្វេភាគី ដើម្បីបំពេញលើចំណែករបស់ខ្លួនរបស់សាលាក្តីនេះទេ និងបានបន្ថែមថា *"យើងនៅកំពុងអំពាវនាវរកការផ្តល់វិភាគទាននៅឡើយ។ យើងកំពុងព្យាយាមរកច្រកផ្សេងទៀត ហើយការផ្តល់ជំនួយដោយជប៉ុន គឺជាមធ្យោបាយចុងក្រោយ"* ។

ទាក់ទិននឹងបញ្ហាថវិកានេះដែរ រាជរដ្ឋាភិបាលចក្រភពអង់គ្លេសនឹងផ្តល់ប្រាក់ចំនួន២លាន៦សែនដុល្លារសហរដ្ឋអាមេរិកទៀត ទៅលើបដិភាគខាងអង្គការសហប្រជាជាតិបន្ថែម

ទៅលើថវិកាសាលាក្តីខ្មែរក្រហម។ ដោយឡែក កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ កន្លងទៅ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានព្រមានថានឹងមិនមានការកាត់ក្តីខ្មែរក្រហម បើសិនមិនមានថវិកាផ្តល់ដោយសហគមន៍អន្តរជាតិ ដោយសង្កត់ធ្ងន់ថាប្រទេសកម្ពុជាជាប្រទេសក្រីក្រ ហេតុអ្វីបានជាមិនផ្តល់មកកម្ពុជា ។ ដូចនេះមកទល់ពេលនេះ បញ្ហាថវិកាសំរាប់ដំណើរការសាលាក្តីខ្មែរក្រហមនៅតែជាបញ្ហាប្រឈមមុខ និងមិនទាន់មានការបញ្ជាក់ណាមួយពីខាងភាគីរាជរដ្ឋាភិបាលនៅឡើយទេអំពីបញ្ហានេះ ដែលជាហេតុនាំឱ្យដំណើរការសាលាក្តីត្រូវពន្យារជាបន្តបន្ទាប់។

## អាស៊ានអាចដើរតួនាទីយ៉ាង សំខាន់ក្នុងដំណើរការសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម

ការចូលរួមចំណែករបស់សហគមន៍អន្តរជាតិមានសារៈសំខាន់ណាស់ ដើម្បីឱ្យសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមអាចដំណើរការទៅមុខបាន។ ក្រៅពីថវិកាបដិភាគដែលត្រូវបានបំពេញដោយភាគីអង្គការសហប្រជាជាតិចំនួន៤៨លានដុល្លារសហរដ្ឋអាមេរិកនៃថវិកាសាលាក្តីសរុប ថវិកាបដិភាគរបស់ភាគីរាជរដ្ឋាភិបាលកម្ពុជា នៅមិនទាន់បានបំពេញបង្គ្រប់នៅឡើយទេ។

ថ្វីត្បិតតែនៅក្នុងតំណាក់មួយដែលបញ្ហាថវិកានៅមិនទាន់មានភាពច្បាស់លាស់ក៏ដោយការរួមវិភាគទានរបស់ប្រទេសផ្សេងៗទៅលើដំណើរការរបស់សាលាក្តីខ្មែរក្រហមមានសារៈសំខាន់ដូចជាបណ្តាសមាគមនៃបណ្តាប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថា "អាស៊ាន" ជាដើម ។ ដូចអ្វីដែលលោក **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងពីតួនាទីរបស់អាស៊ាន ដែលអាចចូលរួមនៅក្នុងដំណើរការរបស់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម។

ដោយសារបណ្តាប្រទេសសមាជិកអាស៊ានមិនទាន់បានរួមចំណែកផ្នែកហិរញ្ញវត្ថុក្នុងកិច្ចដំណើរការសាលាក្តីខ្មែរក្រហម ប៉ុន្តែបណ្តាប្រទេសសមាជិកអាស៊ាននេះដើរតួនាទីសំខាន់ក្នុងការផ្តល់នូវវិភាគទានតាមរយៈមធ្យោបាយមិនមែនថវិកាដូចជាៈ ជំនួយបច្ចេកទេស ការរក្សាទុកឯកសារ/តំកល់ឯកសារ ការផ្សះផ្សាផ្លូវចិត្តដល់ជនរងគ្រោះ ការផ្តល់សំភារៈនិងកុំព្យូទ័រសំរាប់ប្រើប្រាស់ផ្នែករដ្ឋបាល ឬសំរាប់សាកលវិទ្យាល័យ ឬអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ និង វិទ្យាសាស្ត្រនយោបាយ មធ្យោបាយដឹកជញ្ជូនអ្នកធ្វើការស្ម័គ្រចិត្ត ការផ្សព្វផ្សាយតាមវិទ្យុនូវព័ត៌មានទាក់ទងដំណើរការសាលាក្តីខ្មែរក្រហម និងបញ្ហាពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹង និងសារៈប្រយោជន៍របស់សាលាក្តីនេះទៅដល់ប្រជាពលរដ្ឋខ្មែរទូទៅឱ្យបានកាន់តែទូលំទូលាយ។

*( ប្រភពៈ មជ្ឈមណ្ឌលឯកសារកម្ពុជា )*

## អង្គការសហប្រជាជាតិ អំពាវនាវឱ្យចាត់បញ្ជូនមន្ត្រីចូលបំរើសាលាក្តីខ្មែរក្រហម

អង្គការសហប្រជាជាតិបានអំពាវនាវឱ្យបណ្តាប្រទេសជាសមាជិកឱ្យបញ្ជូនឈ្មោះចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិសំរាប់បំរើការនៅក្នុងអង្គជំនុំជំរះវិសាមញ្ញ ឬសាលាក្តីខ្មែរក្រហម។ ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិទាំងអស់មាន៩រូបនឹងធ្វើជាដៃគូជាមួយនឹងចៅក្រម និង ព្រះរាជអាជ្ញាខ្មែរ ដែលមានចំនួនទាំងអស់ ១២ រូប។ ជាការពិតចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិដែលនឹងត្រូវតែងតាំងទាំង៩រូបនេះនឹងដើរតួនាទីដ៏សំខាន់ ដើម្បីធ្វើការរួមគ្នាជាមួយដៃគូរបស់ខ្លួន ក្នុងការធានាថាអង្គជំនុំជំរះវិសាមញ្ញមានលក្ខណៈស្របតាមបទដ្ឋានអន្តរជាតិ ដោយរួមទាំងការគោរពសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធមិ និងប្រសិទ្ធភាពក្នុងការការពារជនរងគ្រោះ និងសាក្សីទាំងឡាយដែលចូលរួម។ ដូចគ្នានេះដែរ អង្គការលើកលែងទោសអន្តរជាតិ ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ក៏បានអំពាវនាវឱ្យបណ្តាប្រទេសសមាជិកអង្គការសហប្រជាតិចាត់តាំងបញ្ជូនបេក្ខភាពចៅក្រម និងព្រះរាជអាជ្ញាដែលមានលក្ខណៈសម្បត្តិល្អ ដើម្បីចូលរួមនៅក្នុងអង្គជំនុំជំរះវិសាមញ្ញនេះដែរ។

ដូច្នេះការជ្រើសរើសបាននូវបេក្ខជនចៅក្រម ដែលមានលក្ខណៈសម្បត្តិខ្ពស់ និងមានឯករាជ្យភាព សំរាប់បំរើការងារនៅក្នុងអង្គជំនុំជំរះវិសាមញ្ញនេះនឹងអាចធ្វើឱ្យមានភាពជោគជ័យនៅក្នុងការស្វែងរកយុត្តិធមិជូនជនរងគ្រោះ ព្រមទាំងទទួលបាននូវការទទួលស្គាល់អង្គជំនុំជំរះនេះពីមជ្ឈដ្ឋានជាតិ និងមជ្ឈដ្ឋានអន្តរជាតិទៀតផង។ ( *ប្រភពៈ សេចក្តីថ្លែងការណ៍ជាសាធារណៈ របស់អង្គការលើកលែងទោសអន្តរជាតិ ថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០០៥*)

# សំណួរ និងចំលើយអំពីបញ្ហានានាទាក់ទិនអង្គជំនុំជំរះវិសាមញ្ញ ឬសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម

## តើសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហមជាអ្វី?

អង្គជំនុំជំរះវិសាមញ្ញ ឬ សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាអង្គជំនុំជំរះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺ សាលាដំបូង និងតុលាការកំពូល ដើម្បីជំនុំជំរះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងពេលពី ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩។

## តើការបង្កើតសាលាក្ដីនេះផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជា?

អស់រយៈពេលជាង ២៦ឆ្នាំ ហើយ ដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំយុត្តិធម៌មួយដែលបានមកពីការកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចនេះ ការបង្កើតសាលាក្ដីនេះមានសារៈសំខាន់ណាស់ចំពោះប្រទេស និងប្រជាជនកម្ពុជា ដូចជាៈ

- ផ្ដល់យុត្តិធម៌ជូនប្រជាជនកម្ពុជា ទាំងអ្នកដែលបាត់បង់ជីវិត និងអ្នកដែលនៅរស់។ គេសង្ឃឹមថាការកាត់សេចក្ដីប្រកបដោយយុត្តិធម៌នឹងជួយធ្វើឱ្យអ្នកដែលនៅរស់ពីការសំលាប់រង្គាលបានធូរស្បើយពីរបួសអតីតកាល ។
- អប់រំប្រជាពលរដ្ឋកម្ពុជាជំនាន់ក្រោយឱ្យយល់ដឹងពីទំព័រប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យនេះ និងចៀសវាងការប្រព្រឹត្តខុសដូចនេះទៀត ។
- ពង្រឹងនីតិរដ្ឋរបស់យើង ព្រមទាំងជាឧទាហរណ៍មួយសំរាប់អ្នកទាំងឡាយណា ដែលមិនគោរពច្បាប់ទាំងនៅកម្ពុជា និងសំរាប់របបឃោរឃៅនៅទូទាំងពិភពលោក។ ដូចនេះឧក្រិដ្ឋជននឹងយល់ដឹងថា ពួកគេនឹងត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រសិនបើគេបានប្រព្រឹត្តអំពើនោះ។
- ស្វែងរកការពិតជូនជនរងគ្រោះឱ្យបានដឹងពីមូលហេតុដែលនាំឱ្យមានអំពើឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅនេះ។
- ជាគំរូដល់សាលាក្ដីក្នុងស្រុក ដើម្បីរួមវិភាគទានក្នុងការកែទំរង់ប្រព័ន្ធយុត្តិធម៌ឱ្យបានកាន់តែល្អប្រសើរ និងឱ្យកាន់តែមានទំនុកចិត្តពីប្រជាពលរដ្ឋ និង សហគមន៍អន្តរជាតិ។
- ចូលរួមវិភាគទានក្នុងការស្តារសង្គមជាតិឡើងវិញ តាមរយៈការបង្កើនការយល់ដឹងឱ្យកាន់តែទូលំទូលាយស្ដីពីសាលាក្ដីនេះទៅដល់ប្រជាពលរដ្ឋនិងប្រែក្លាយពីការឈឺចាប់ទៅជាការផ្សះផ្សាជាតិ សន្តិភាព និងអភិវឌ្ឍន៍សង្គមកម្ពុជាទាំងមូលនាពេលអនាគត ។
- លុបបំបាត់ចោលនូវវប្បធម៌និទណ្ឌភាពនៅកម្ពុជា ។

## តើការបង្កើតសាលាក្ដីកាត់ក្ដីមេដឹកនាំខ្មែរក្រហមដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមបានចាប់ផ្ដើមតាំងពីពេលណា?

នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជា ដែលកាលនោះដឹកនាំដោយសហនាយករដ្ឋមន្ត្រី សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និង សម្ដេច ហ៊ុន សែន បានចរចាជាមួយអង្គការសហប្រជាជាតិ ដើម្បីរៀបចំបង្កើតសាលាជំរះក្ដីមួយ កាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការព្រមព្រៀងចុងក្រោយរវាងភាគីទាំងពីរ គឺការបង្កើតសាលាក្ដី ចំរុះជាតិ និងអន្តរជាតិមួយ ដែលហៅថា "អង្គជំនុំជំរះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា"។ ដូច្នេះ វាបានប្រើប្រាស់រយៈពេលយ៉ាងយូរ ដើម្បីសិក្សានូវបញ្ហាលំអិតផ្សេងៗជាច្រើននៃប្រភេទតុលាការថ្មីមួយនេះ។ រហូតមកដល់ឆ្នាំ ១៩៩៩ ទើបរាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងក្រុមការងារមួយដើម្បីរៀបចំការកាត់សេចក្ដីនិងធ្វើការចរចាជាមួយអង្គការសហប្រជាជាតិ។ នៅឆ្នាំ២០០៣ ភាគីទាំងពីរបានឯកភាពព្រមព្រៀងគ្នាលើការបង្កើតសាលាក្ដីនេះ ដោយបានប្រើប្រាស់ពេលដ៏យូរ ព្រមទាំងការខ្វែងមតិគ្នា និងយល់ច្រឡំច្រើនលើកច្រើនសា។

## តើជនណាខ្លះនឹងត្រូវនាំយកមកធ្វើការកាត់ទោសនៅចំពោះមុខអង្គជំនុំជំរះវិសាមញ្ញ?

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញកំណត់ថា ការជំនុំជំរះទោសគឺធ្វើឡើងចំពោះតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលបានរៀបចំផែនការ ឬចេញបទបញ្ជា និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ។ ដូច្នេះ អង្គជំនុំជំរះនេះ នឹងសំរេចថាតើខ្មែរក្រហមណាជា *"មេដឹកនាំជាន់ខ្ពស់"* ហើយអ្នកណា ដែលជា **អ្នកទទួលខុសត្រូវជាងគេក្នុងបទឧក្រិដ្ឋ** នៅក្នុងរបបនោះ។ ម្យ៉ាងទៀត តុលាការនេះ នឹងស្វែងរកតែមុខសញ្ញាទាំងនេះ គឺមិនមែនស្វែងរកគ្រប់អតីតសមាជិកខ្មែរក្រហម ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមកាន់អំណាចនោះទេ។

## តើមានបទល្មើសអ្វីខ្លះដែលនឹងត្រូវចោទប្រកាន់នៅចំពោះមុខអង្គជំនុំជំរះនេះ?

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញសំរាប់កាត់ទោស

មេដឹកនាំខ្មែរក្រហមចែងពីបទឧក្រិដ្ឋដែលនឹងត្រូវធ្វើការចោទប្រកាន់រួមមានដូចជាៈ *បទឧក្រិដ្ឋក្នុងស្រុក និង បទឧក្រិដ្ឋអន្តរជាតិ*។ ករណីបទឧក្រិដ្ឋក្នុងស្រុក គឺជាបទឧក្រិដ្ឋទាំងឡាយណាដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដូចជា : មនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា។ ចំនែកឯបទឧក្រិដ្ឋអន្តរជាតិរួមមានដូចជាៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ បទល្មើសបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌និងបទឧក្រិដ្ឋប្រឆាំងទៅលើអ្នកដែលទទួលបានការពារជាអន្តរជាតិដោយយោងតាមអនុសញ្ញាទីក្រុងវីយែន ឆ្នាំ ១៩៦១។

### តើជនសង្ស័យនឹងទទួលនូវការដាក់ទោសយ៉ាងដូចម្តេចប្រសិនបើគេត្រូវបានកាត់សេចក្តីថាមានទោសនោះ?

យោងទៅតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញ ការដាក់ទោសអតិបរមា គឺ ទោសមួយជីវិត ចំណែកការដាក់ទោសជាអប្បរមា គឺដាក់គុករយៈពេល៥ឆ្នាំ។ នៅក្នុងច្បាប់នេះមិនចែងពីការកាត់ទោសប្រហារជីវិតទេ ពីព្រោះការកាត់ទោសប្រហារជីវិត គឺខុសនឹងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ តុលាការអាចបញ្ជាឱ្យធ្វើការរឹបអូសទ្រព្យសម្បត្តិ ឬ ថវិកា ដែលជនជាប់ចោទទទួលបានមិនស្របច្បាប់ ឬ ដោយការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ហើយទ្រព្យសម្បត្តិដែលបានរឹបអូសនេះនឹងត្រូវប្រគល់ជូនទៅរដ្ឋ។

### តើមានការលើកលែងទោស ឬមានការអនុគ្រោះទោសចំពោះមុខអង្គជំនុំជំរះវិសាមញ្ញដែរឬទេ?

នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញ និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា កំនត់ថា រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសរួចជាស្រេចហើយនឹងមិនស្នើសុំការលើកលែងទោស ឬការអនុគ្រោះទោសសំរាប់ជនណាម្នាក់ដែលត្រូវធ្វើការស៊ើបអង្កេត ឬត្រូវបានកាត់សេចក្តីថាមានទោសនៅក្នុងអង្គជំនុំជំរះវិសាមញ្ញឡើយ។ ដូច្នេះ នឹងមិនមានការសុំលើកលែងទោស ឬអនុគ្រោះទោសចំពោះជនណាមួយ ដែលត្រូវបានតុលាការសំរេចថាមានទោសនោះឡើយ។

### តើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាខ្លះដែលត្រូវបានធ្វើការកាត់ក្តីរួចហើយ?

កាលនៅឆ្នាំ ១៩៧៩ តុលាការប្រជាជនបដិវត្តន៍បានកាត់សេចក្តីអំពើប្រល័យពូជសាសន៍ទៅលើមេដឹកនាំខ្មែរក្រហមពីររូបគឺ **អៀង សារី និង ប៉ុល ពត** ដោយបានរកឃើញថា ពួកគេទាំងពីរជាប់ពិរុទ្ធខាងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ប៉ុន្តែអ្នកទាំងពីរអវត្តមាននៅចំពោះមុខតុលាការនេះ ហើយក៏មិនបានទទួលទោសពីកំហុសដែលខ្លួនបានប្រព្រឹត្តនោះដែរ។ នាពេលនោះដែរ តុលាការនេះមិនបានទទួលស្គាល់ពីអន្តរជាតិទេ។ នៅឆ្នាំ ១៩៩៦ ព្រះមហាក្សត្របានប្រទានការអនុគ្រោះទោសចំពោះ **អៀង សារី** ក្រោយពីបានសមាហរណកម្មចុះចូលរួមរស់ជាមួយរាជរដ្ឋាភិបាល។ ដូចនេះការសំរេចចោទប្រកាន់ឬមិនចោទប្រកាន់រូបគាត់ វាអាស្រ័យទៅលើចៅក្រមធ្វើការសំរេចទៅលើវិសាលភាពនៃការអនុគ្រោះទោសនេះ។ ហើយម៉្យាងទៀតប្រសិនបើ អៀង សារី មិនអាចកាត់ទោសឡើងវិញ ពីបទប្រល័យពូជសាសន៍ក៏ដោយ ក៏អាចនៅមានបទចោទប្រកាន់ផ្សេងៗទៀត ដែលគេអាចលើកឡើងប្រឆាំងរូបគាត់បានវាអាស្រ័យទៅលើភស្តុតាងដែលគេអាចរកបាន។ គួរបញ្ជាក់ថា កាលពីឆ្នាំ ១៩៩៧ ពួកខ្មែរក្រហមខ្លួនឯងផ្ទាល់បានកាត់ទោស ប៉ុល ពត ពីបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្តនៅក្នុងរង្វង់អង្គការរបស់គេក្រោយឆ្នាំ ១៩៧៩ ម្តងរួចមកហើយ។ នៅឆ្នាំ ១៩៩៨ ប៉ុល ពត បាន ស្លាប់ដោយសារជំងឺ ហេតុដូច្នេះអង្គជំនុំជំរះវិសាមញ្ញមិនអាចធ្វើការកាត់ទោសរូបគាត់បានទេ ។

### តើប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ជាប់ពាក់ព័ន្ធជាមួយរបបកម្ពុជាប្រជាធិបតេយ្យនៅ មុនឆ្នាំ ១៩៧៥ ត្រូវប្រឈមមុខនឹងការកាត់ក្តីនៅចំពោះមុខអង្គជំនុំជំរះនេះដែរឬទេ?

អង្គជំនុំជំរះវិសាមញ្ញអាចកាត់សេចក្តីតែបុគ្គលណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ។ ហេតុដូចនេះ អង្គជំនុំជំរះនេះ មិនមានយុត្តាធិការធ្វើការកាត់សេចក្តីទៅលើប្រទេសណាមួយ ឬអង្គការណាមួយបានឡើយ។

### តើអង្គជំនុំជំរះវិសាមញ្ញអាចកាត់ក្តីចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែរឬទេ?

យុត្តាធិការរបស់អង្គជំនុំជំរះវិសាមញ្ញមានព្រំដែនកំណត់។ ហើយនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញកំណត់យ៉ាងច្បាស់ថា អង្គជំនុំជំរះនេះអាចកាត់សេចក្តីតែឧក្រិដ្ឋកម្មណា ដែលបានប្រព្រឹត្តនៅកម្ពុជាក្នុងចន្លោះ ថ្ងៃទី ១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃទី ៦ មករា ១៩៧៩ តែប៉ុណ្ណោះ។ ប៉ុន្តែ តុលាការកម្ពុជាបច្ចុប្បន្នមានអំណាចនឹងកាត់សេចក្តីលើឧក្រិដ្ឋកម្មទាំងអស់នេះ ។ ជាឧទាហរណ៍ អំពីការកាត់ក្តីនាយទាហានខ្មែរក្រហម ដែលទទួលខុសត្រូវពីបទពួនស្ទាក់វាយប្រហាររថភ្លើងពីភ្នំពេញទៅខេត្តកំពតនៅឆ្នាំ ១៩៩៤ ដែលបានសំលាប់ប្រជាពលរដ្ឋចំនួន ១១ នាក់ និង ចំណាប់ខ្មាំងបរទេសចំនួនបីនាក់ ត្រូវបានកាត់ទោសដោយតុលាការក្នុងស្រុក។ ក្នុងករណីនេះដែរ អតីតឧត្តមសេនីយ៍ខ្មែរក្រហម ឈ្មោះ **សំ ប៊ិត** និង **នួន ប៉ែត** និង វរសេនីយ៍ឯក **ឈូក រិន** ត្រូវបានតុលាការរកឃើញថាមានជាប់ពិរុទ្ធភាពដែរ ។ (*ប្រភពៈ "ការណែនាំបំភ្លឺអំពីការជំនុំជំរះក្តីមេដឹកនាំខ្មែរក្រហម" រៀបចំដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលទៅទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០០៤*)

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសាលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អិន.អ៊ី.ឌី (NED) ទេ ។*

**ឧបត្ថម្ភមូលនិធិដោយៈ អ៊ិន.អ៊ី.ឌី**

The National Endowment for Democracy
*Supporting freedom around the world*